មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

# របាយការណ៍

## កិច្ចពិភាក្សាតុមូល ក្រោមប្រធានបទ «ការវាយតម្លៃជុំវិញការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា»

***(ASSESSING THE IMPLICATIONS OF CAMBODIAS LEAST DEVELOPED***

ភ្ជាប់ទំនាក់ទំនង៖

ចូលទៅកាន់គេហទំព័រ៖
https://cd-center.org

***របាយការណ៍***

***កិច្ចពិភាក្សាតុមូល ស្ដីពី***

# «ការវាយតម្លៃជុំវិញការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា

## ( Assessing the Implications of Cambodia’s Least Developed Country Graduation )»

*ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤*

*© រក្សាសិទ្ធិដោយ ម.អ.ក | ២០២៤*

# តារាងនៃមាតិកា


**អំពីមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា** ... 4

**ទិដ្ឋភាពទូទៅនៃកិច្ចពិភាក្សាតុមូល** ... 5

**អំពីវាគ្មិនពិភាក្សា និងអ្នកសម្របសម្រួល** ... 6

**អនុសាសន៍សំខាន់ៗ របស់តួអង្គនៃកិច្ចពិភាក្សាតុមូល** ... 7

I. **សុន្ទរកថាបើក** ... 9

II. **សម្រង់ខ្លឹមសារកិច្ចពិភាក្សាតុមូលៈ «ការវាយតម្លៃការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច»** ... 11

**ដំណើរការនៃចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច** ... 11

**ដំណើរការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា** ... 12

**អត្ថប្រយោជន៍ និងយន្តការគាំទ្រចំពោះកម្ពុជា** ... 13

**បញ្ហាប្រឈមមកលើកម្ពុជា ក្រោយការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួច** ... 14

**សេចក្តីសន្និដ្ឋាន** ... 15

**អនុសាសន៍** ... 17

III. **សុន្ទរកថាបិទ** ... 19

IV. **ឧបសម្ព័ន្ធទី១ៈ របៀបវារៈនៃកម្មវិធីកិច្ចពិភាក្សាតុមូល** ... 21

# អំពីមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា គឺជាស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញ ដែលមានសកម្មភាពការងារធំៗចំនួន ០៣ រួមមាន៖

១) ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ

២) ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ និង

៣) ការចូលរួមការអភិវឌ្ឍគោលនយោបាយ។

## ចក្ខុវិស័យ

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា មានចក្ខុវិស័យជាស្ថាបនិក៖ “ចូលរួមប្រកបដោយមូលដ្ឋានពិត វិទ្យាសាស្រ្ត និងវិជ្ជាជីវៈ សម្រាប់កម្ពុជាជាប្រទេសអភិវឌ្ឍន៍”។

## បេសកកម្ម

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ផ្តោតលើការចូលរួមក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងសន្តិភាព ជាពិសេសនៅ ព្រះរាជាណាចក្រកម្ពុជា តាមរយៈការស្រាវជ្រាវតាមបែបវិទ្យាសាស្រ្ត ការអភិវឌ្ឍគោលនយោបាយជាតិ និងអន្តរជាតិ និងការកសាងសមត្ថភាពធនធានមនុស្សក្នុងបរិបទនៃសកលភាវូបនីយកម្ម និងតំបន់ស៊ីជម្រៅនាពេលបច្ចុប្បន្ន ព្រមទាំងការកើនឡើងគួរឱ្យកត់សម្គាល់នៃភាពស្មុគស្មាញនៃការអភិវឌ្ឍគោលនយោបាយអន្តរជាតិ។



# ទិដ្ឋភាពទូទៅនៃកិច្ចពិភាក្សាតុមូល

## “ការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា”

តាមរយៈការត្រួតពិនិត្យ (Triennial Review) ដោយគណៈកម្មការអង្គការសហប្រជាជាតិស្តីពីគោលនយោបាយអភិវឌ្ឍន៍ ក្នុងឆ្នាំ២០២១ កម្ពុជាត្រូវបានវាយតម្លៃថា អាចចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួច ជាលើកទី១។ ជាវឌ្ឍនភាព ក្នុងឆ្នាំ២០២៤នេះ កម្ពុជា ទទួលបានជោគជ័យក្នុងការវាយតម្លៃជាលើកទី២និងត្រូវបានគេរំពឹងថាអាចនឹងចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចយ៉ាងយូរត្រឹមឆ្នាំ២០២៧ ជាមួយនឹងរយៈពេលអន្តរកាលចន្លោះពី ៣-៥ឆ្នាំ។

ការណ៍នេះ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយ ដែលបង្ហាញពីសមិទ្ធផលនៃដំណើរការអភិវឌ្ឍ របស់កម្ពុជាក្នុងរយៈពេល ២៥ឆ្នាំ នៃការបន្តការអភិវឌ្ឍ និងកែលម្អ លើគ្រប់វិស័យអាទិភាពនានា។ ការចាកចេញនេះ គឺជាការផ្លាស់ប្តូរមួយ ដែលជាបច្ច័យអវិជ្ជមាន និងវិជ្ជមាន។ ការណ៍នេះមានភាពចាំបាច់សម្រាប់រដ្ឋាភិបាលក្នុងការដាក់ចេញយុទ្ធសាស្ត្រត្រៀមខ្លួន និងកំណែទម្រង់គោលនយោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈម និងកាលានុវត្តភាព ជាពិសេសបន្តជំរុញការអភិវឌ្ឍជាតិ ដើម្បីទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០។



## គោលបំណង

- បង្កើតជាការពិភាក្សា និងផ្លាស់ប្តូរយោបល់ដោយតុល្យភាព គ្រប់ជ្រុងជ្រោយ និងប្រកបដោយបរិយាប័ន្ន ដើម្បី**កំណត់ការងារអាទិភាពសម្រាប់កម្ពុជា** ក្នុងការត្រៀមខ្លួនចាកចេញពីឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច
- **កំណត់ទិសដៅយុទ្ធសាស្ត្រទៅមុខ**សម្រាប់ដំណើរអភិវឌ្ឍន៍របស់ខ្លួន ព្រមទាំងត្រៀមខ្លួនក្នុងការចាប់យកកាលានុវត្តភាព និងឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា
- បង្កើតវេទិកាសម្រាប់ចែករំលែកចំណេះ និង**ការសន្ទនារវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងធនាគារខួរក្បាល** ដើម្បីផ្តល់ជាធាតុចូលដល់ដំណើរការបង្កើតគោលនយោបាយ និងអន្តរាគមន៍របស់រាជរដ្ឋាភិបាល។

## ភាពចម្រុះនៃ សមាសភាពចូលរួម






# អំពីវាគ្មិនពិភាក្សា និងអ្នកសម្របសម្រួល



## លោកសាស្ត្រាចារ្យជំនួយ បណ្ឌិត យន់ គា

### អ្នកសម្របសម្រួល

**លោកបណ្ឌិត យន់ គា** បច្ចុប្បន្ន ជានាយករងវិទ្យាស្ថានសិក្សាអន្តរជាតិ និងគោលនយោបាយសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

ប្រវត្តិសិក្សារបស់**លោកបណ្ឌិត** រួមមានបរិញ្ញាបត្រផ្នែកអប់រំ (TEFL) ពីវិទ្យាស្ថានភាសាបរទេស នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកទំនាក់ទំនងអន្តរជាតិ និងបណ្ឌិតផ្នែកសិក្សាអន្តរជាតិពីសាកលវិទ្យាល័យ Waseda ប្រទេសជប៉ុន។ លើសពីនេះ **លោកបណ្ឌិត** បានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យវេជ្ជសាស្ត្រ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។ វិស័យស្រាវជ្រាវរបស់**លោកបណ្ឌិត** រួមមានអន្តរភាវូបនីយកម្មនៃការអប់រំឧត្តមសិក្សា ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការលើវិស័យអប់រំអន្តរជាតិ និងសេដ្ឋកិច្ចនយោបាយអន្តរជាតិ។



## ឯកឧត្តមបណ្ឌិត គី សេរីវឌ្ឍន៍

### អ្នកពិភាក្សា

**ឯកឧត្តមបណ្ឌិត គី សេរីវឌ្ឍន៍** ជាប្រធានវិទ្យាស្ថានសិក្សាចិន នៃរាជបណ្ឌិត្យសភាកម្ពុជា និងជាសមាជិកមិនអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម-វប្បធម៌។ **ឯកឧត្តមបណ្ឌិត** ទទួលបានសញ្ញាប័ត្របណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យជាតិឆាងវ៉ុន នៃសាធារណរដ្ឋកូរ៉េ ក្នុងឆ្នាំ២០១១។ **ឯកឧត្តមបណ្ឌិត** ក៏ត្រូវបានជ្រើសរើសជា Visiting Professor នៅសាកលវិទ្យាល័យជាតិឆាងវ៉ុន ឆ្នាំ២០១២។ **ឯកឧត្តមបណ្ឌិត** ទទួលបានងារជាសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យ CamEd Business School ក្នុងឆ្នាំ ២០១៨។ នៅឆ្នាំ២០១៩ **ឯកឧត្តមបណ្ឌិត** គឺជាអ្នកចូលរួមក្នុងការប្រកួតប្រជែងផ្នែកមីក្រូសេដ្ឋកិច្ច (MOC) ដែលត្រូវបានរៀបចំឡើងដោយសាស្ត្រាចារ្យ Michael Porter នៅសាលាពាណិជ្ជកម្ម Harvard សហរដ្ឋអាមេរិក។ **ឯកឧត្តមបណ្ឌិត** មានបទពិសោធន៍បង្រៀនមុខវិជ្ជាសេដ្ឋកិច្ចនៅសាកលវិទ្យាល័យល្បីៗជាច្រើននៅកម្ពុជា។

ចំណាប់អារម្មណ៍ស្រាវជ្រាវចម្បងរបស់ **ឯកឧត្តមបណ្ឌិត** ផ្តោតទៅលើប្រធានបទដូចជា ប្រាក់ឈ្នួលអប្បបរមា និងការប្រកួតប្រជែង ការវិនិយោគ កំណើនសេដ្ឋកិច្ច សមាហរណកម្មសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងពាណិជ្ជកម្ម។ បច្ចុប្បន្ន **ឯកឧត្តមបណ្ឌិត** កំពុងធ្វើការវាយតម្លៃ និងវិភាគលើអន្តរវិស័យនៃសេដ្ឋកិច្ចកម្ពុជា។ **ឯកឧត្តមបណ្ឌិត** បានធ្វើការស្រាវជ្រាវជាច្រើននៅក្នុងប្រទេសកម្ពុជា បរទេស និងវិទ្យាស្ថានអន្តរជាតិ ដូចជា កាណាដា កូរ៉េ វៀតណាម និងចិន EuroCham Amro និង Jetro។



## អ្នកស្រីបណ្ឌិត អ៊ុច ច័ន្ទតារ៉ានី

### អ្នកពិភាក្សា

**អ្នកស្រីបណ្ឌិត អ៊ុច ច័ន្ទតារ៉ានី** ជាសេដ្ឋវិទូនៅការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិ និងសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ **អ្នកស្រីបណ្ឌិត** មានបទពិសោធន៍ការងារជាច្រើនពាក់ព័ន្ធនឹងសេដ្ឋកិច្ច-សង្គម និងការអភិវឌ្ឍ រួមទាំងគោលនយោបាយសេដ្ឋកិច្ច-សង្គម និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួច ការធ្វើបរិវត្តកម្មសេដ្ឋកិច្ច បដិវត្តន៍ឧស្សាហកម្មទី៤ សមាហរណកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មក្នុងតំបន់។

មុនពេលចូលបម្រើការងារនៅ UNRCO ប្រចាំកម្ពុជា **អ្នកស្រីបណ្ឌិត** ធ្លាប់ជាសេដ្ឋវិទូប្រចាំប្រទេសមីយ៉ាន់ម៉ា កម្ពុជា និងជាសមាជិកក្រុមដឹកជញ្ជូន និងភស្តុភាររបស់ឡាវ ក្រោមកម្មវិធីអាហារូបករណ៍អាស៊ីប៉ាស៊ីហ្វិករបស់ធនាគារពិភពលោក សេដ្ឋវិទូជាតិ នៃកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា, ជាប្រធានផ្នែកស្រាវជ្រាវសេដ្ឋកិច្ច នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និងជាប្រធានកម្មវិធីជាន់ខ្ពស់នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា។

**អ្នកស្រីបណ្ឌិត អ៊ុច ច័ន្ទតារ៉ានី** ទទួលបានសញ្ញាប័ត្របណ្ឌិតផ្នែកសេដ្ឋកិច្ច ពីសាកលវិទ្យាល័យ Monash នៃប្រទេសអូស្ត្រាលី និងទទួលបានសញ្ញាប័ត្រអនុបណ្ឌិតផ្នែកគោលនយោបាយសាធារណៈ ពីមហាវិទ្យាល័យគោលនយោបាយសាធារណៈ Lee Kuan Yew នៃសាកលវិទ្យាល័យជាតិសិង្ហបុរី។

# អនុសាសន៍សំខាន់ៗ របស់តួអង្គនៃកិច្ចពិភាក្សាតុមូល



"

កម្ពុជា បច្ចុប្បន្ន កំពុងស្ថិតលើរបត់ថ្មីមួយ។ រដ្ឋសភាជាតិដែលកើតចេញពីការបោះឆ្នោតប្រកបដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ កាលពីខែកក្កដា ឆ្នាំ២០២៣ កន្លងទៅ បានបង្កើតរាជរដ្ឋាភិបាលបន្តវេន ដែលពោរពេញទៅដោយសមត្ថភាព ឆន្ទៈខ្ពស់ និងភាពស្វាហាប់ក្នុងការបន្តថែរក្សាសមិទ្ធផលចាស់ និងបង្កើតសមិទ្ធផលថ្មីៗបន្ថែមទៀត។ ដំណើររបស់កម្ពុជា ក្នុងការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចនេះ គឺជាវិញ្ញាសាជាក់ស្ដែងមួយ ដែលថ្នាក់ដឹកនាំជំនាន់ក្រោយត្រូវខិតខំប្រឹងប្រែងបំពេញបន្ថែមលើសមិទ្ធផល ដែលថ្នាក់ដឹកនាំជំនាន់មុនបានបន្សល់ទុក ដើម្បីសម្រេចបាននូវចក្ខុវិស័យកម្ពុជា២០៣០ និង២០៥០ នាពេលខាងមុខ។

ឯកឧត្តមបណ្ឌិត អ៊ុន ឃាង
រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា



"

ការដែលកម្ពុជា នឹងចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច បានបញ្ជាក់ឱ្យឃើញនូវការដឹកនាំដ៏ឈ្លាសវៃ និងគោលនយោបាយដ៏ត្រឹមត្រូវ ជាពិសេសការអនុវត្តគោលនយោបាយឈ្នះឈ្នះ ដែលនាំមកនូវការបញ្ចប់សង្គ្រាមស៊ីវិល របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិមុនៗ ដែលដឹកនាំដោយសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងរាជរដ្ឋាភិបាលថ្មី ដែលដឹកនាំដោយសម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត។

លោកសាស្ត្រាចារ្យជំនួយ បណ្ឌិត យន់ គា
អនុប្រធានវិទ្យាស្ថានសិក្សាអន្តរជាតិ និងគោលនយោបាយសាធារណៈ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

# អនុសាសន៍សំខាន់ៗ របស់តួអង្គនៃកិច្ចពិភាក្សាតុមូល

"វិស័យកសិកម្ម និងវិស័យឧស្សាហកម្ម គឺជាកត្តាដ៏មានឥទ្ធិពលក្នុងការជំរុញសេដ្ឋកិច្ចកម្ពុជា។ ប្រសិនបើកម្ពុជាអាចអភិវឌ្ឍវិស័យកសិកម្ម និងអភិវឌ្ឍឧស្សាហកម្មដែលមិនបំពុលបរិស្ថានឱ្យរឹងមាំ និងផ្សារភ្ជាប់វិស័យអាទិភាពទាំងពីរនេះ ដើម្បីជាយន្តការជំរុញវិស័យទេសចរណ៍ នោះកម្ពុជា នឹងក្លាយជាសួនច្បារពិភពលោក។

ឯកឧត្តមបណ្ឌិត គី សេរីវឌ្ឍន៍
ប្រធានវិទ្យាស្ថានសិក្សាចិននៃរាជបណ្ឌិត្យសភាកម្ពុជា





"អនុសាសន៍ ៣ចំណុច សម្រាប់ជាការពិចារណា និងគិតគូរបន្ថែមលើដំណើរការនៃការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា៖

១. ពង្រីកការបញ្ជ្រាបការយល់ដឹងក្នុងចំណោមភាគីពាក់ព័ន្ធ ផ្ដោតលើការត្រៀមខ្លួន និងការដាក់ផែនការទទួលយក

២. កិច្ចសហការរវាងបណ្ដាប្រទេសដែលបានចាកចេញពី LDC ដើម្បីចែករំលែកបទពិសោធន៍ ឧត្តមានុវត្តន៍ ព័ត៌មាន និងជំនួយបច្ចេកទេស

៣. ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ តាមរយៈជំនួយហិរញ្ញប្បទាន និងបច្ចេកទេសដើម្បីសម្រួលដល់ការត្រៀមខ្លួន និងសម្របខ្លួនក្រោយចាកចេញ។

លោក សុខន តារាពី
នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា

# I. សុន្ទរកថាបើក

**ឯកឧត្តមបណ្ឌិត អ៊ុន យាង**
**រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
**និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា**

១- សូមគោរពៈ

- **បណ្ឌិត យន់ គា**, នាយករង វិទ្យាស្ថានសិក្សាអន្តរជាតិ និងគោលនយោបាយសាធារណៈ
- **បណ្ឌិត អ៊ុច ចាន់ដារ៉ានី**, សេដ្ឋកិច្ចវិទូ ប្រចាំការិយាល័យអង្គការសហប្រជាជាតិកម្ពុជា
- **បណ្ឌិត គី សេរីវឌ្ឍន៍**, ប្រធាន មជ្ឈមណ្ឌលសិក្សាចិននៃរាជបណ្ឌិត្យសភាកម្ពុជា
- **ឯកឧត្តម សុខន តារាពី**, នាយករង មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
- **ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយស និងក្មួយៗនិស្សិតជាទីមេត្រី!**

២- ថ្ងៃនេះ តាងនាមឱ្យក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយក្រៃលែង ដែលមានឱកាសថ្លែងនៅក្នុងកិច្ចពិភាក្សាតុមូលដ៏មានសារៈសំខាន់នារសៀលនេះ ក្រោមប្រធានបទ **«ការវាយតម្លៃលើការចាកចេញពីឋានៈជាប្រទេសដែលមានការអភិវឌ្ឍតិចតួចរបស់កម្ពុជា»** ក្រោមការផ្តួចផ្តើម និងរៀបចំឡើងដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

៣- សារៈសំខាន់នៃកិច្ចពិភាក្សាតុមូលនេះមានបីចំណុច **ទី១ គឺពេលវេលា** (Timing), **ទី២ គឺការត្រៀមខ្លួន** (Preparedness) **និងទី៣ គឺភាពពាក់ព័ន្ធ** (Relevance)។

៤- កត្តាពេលវេលាៈ កម្ពុជា ដើរបានពាក់កណ្ដាលនៃដំណើរឆ្ពោះទៅសម្រេចបានការចាកចេញពីឋានៈជាប្រទេសដែលមានការអភិវឌ្ឍតិចតួចហើយ។ ជាក់ស្ដែង កាលពីថ្ងៃទី៤-៨ ខែមីនា ឆ្នាំ២០២៤ ថ្មីៗនេះ គណៈកម្មការគោលនយោបាយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ បានរៀបចំការវាយតម្លៃប្រចាំបីឆ្នាំ ជាលើកទីពីរ។ ជាលទ្ធផលឃើញថា កម្ពុជា ពិតជាពេញលក្ខណៈក្នុងការចាកចេញពីឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច។ ខ្ញុំក៏សូមឆ្លៀតឱកាសនេះ ចូលរួមអបអរសាទរជាមួយរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាភាគីពាក់ព័ន្ធទាំងអស់ដែលជាតួអង្គដ៏សំខាន់ក្នុងការជំរុញល្បឿនសេដ្ឋកិច្ចកម្ពុជា ជាពិសេសត្រលប់មកប្រក្រតីភាពវិញយ៉ាងលឿនក្នុងដំណាក់កាលប្រឈមនឹងវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបង្កឡើងដោយជំងឺរាតត្បាតសាកលកូវីដ១៩។ ជំហានបន្ទាប់ កម្ពុជានឹងមានរយៈពេលយ៉ាងយូរបីឆ្នាំ ក្នុងការត្រៀមខ្លួន ពោលគឺយ៉ាងយូរនៅត្រឹមឆ្នាំ២០២៧ កម្ពុជានឹងលែងជាប្រទេសមានការអភិវឌ្ឍតិចតួចហើយ។ យ៉ាងណាមិញ ជាមួយនឹងការរំពឹងទុកប្រកបដោយក្តីសង្ឃឹមនេះ ក៏មានលេចឡើងនូវការពិភាក្សាជុំវិញដំណាក់កាលក្រោយពេលដែលកម្ពុជា ចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច ថាតើនឹងមានបច្ច័យវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះ។ កិច្ចពិភាក្សានារសៀលនេះនឹងផ្ដោតទៅលើបច្ច័យទាំងនេះ។

៥- ការត្រៀមខ្លួនៈ ផ្សារភ្ជាប់ទៅនឹងកត្តាពេលវេលា ការត្រៀមខ្លួនសំដៅទៅលើការ គិតគូរយុទ្ធសាស្ត្រក្នុងការសម្របខ្លួនទៅនឹងបរិបទ និងបរិស្ថានថ្មី ដែលកម្ពុជានឹងត្រូវជួបក្នុងឋានៈថ្មី ដូចជាលក្ខខណ្ឌពាណិជ្ជកម្មអន្តរជាតិ និងជំនួយអន្តរជាតិ កាលានុវត្តភាពថ្មី ព្រមទាំងបញ្ហាប្រឈមដែលអាចជះផលអវិជ្ជមានទាំងក្នុងអំឡុងពេលត្រៀមខ្លួន (២០២៥-២០២៧) និងអំឡុងពេលអន្តរកាល (Transition) ក្រោយឆ្នាំ២០២៧។ ការរៀបចំគិតគូរពីយុទ្ធសាស្ត្រដែលជាកាតព្វកិច្ចស្នូលរបស់រាជរដ្ឋាភិបាល។ ប៉ុន្តែនេះ មិនមែនការកាតព្វកិច្ចរបស់តួអង្គរដ្ឋាភិបាលតែឯងនោះទេ។ តួនាទីរបស់ ដៃគូអភិវឌ្ឍន៍ និងធនាគារខួរក្បាល វិស័យឯកជន ព្រមទាំងសាធារណជនទូទៅ ក៏មិនអាចផ្ដាច់ចេញពីដំណាក់កាលដ៏សំខាន់នេះផងដែរ។ ពោល នេះគឺជាដំណើររួមរបស់សង្គមយើងទាំងមូល ដែលតែងត្រូវបាន

ស្គាល់ថាវិធីសាស្ត្រនៃការចូលរួមរបស់សង្គមទាំងមូល (Whole-of-society approach) ដូចដែលកំពុងប្រើប្រាស់នៅក្នុងវេទិកានាសៀលនេះ តាមរយៈការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ លើសពីស្ថាប័នរដ្ឋាភិបាល។

៦- ភាពពាក់ព័ន្ធ៖ ភាពពាក់ព័ន្ធនៅត្រង់នេះ គឺសំដៅលើភាពពាក់ព័ន្ធនៃកិច្ចពិភាក្សាតុមូល ដែលនឹងចូលរួមផ្តល់ជាធាតុចូល និងអនុសាសន៍ប្រកបដោយអត្ថន័យជូនដល់រាជរដ្ឋាភិបាលសម្រាប់ជាជំនួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រនានា ទាំងក្នុងអំឡុងពេលត្រៀមខ្លួន និងអំឡុងពេលអន្តរកាល (Transition) តាមរយៈទស្សនៈ និងការវិភាគរបស់វាគ្មិនទាំងបីរូបជុំវិញប្រធានបទដែលកំពុងទទួលបានការចាប់អារម្មណ៍មួយនេះ។

៧- មើលឃើញពីសារៈសំខាន់នៃប្រធានបទនេះហើយ ទើបមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា បានគិតគូរផ្តួចផ្តើមឱ្យមានកិច្ចពិភាក្សានេះដោយមានការចូលរួមជាធាតុចូលដ៏មានអត្ថន័យ ពីសំណាក់វាគ្មិនទាំងបីរូបដែលសុទ្ធសឹងជាអ្នកជំនាញមកពីវិស័យផ្សេងៗគ្នាដូចជាស្ថាប័នរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍ និងធនាគារខួរក្បាល ដើម្បីបង្កើតជាការពិភាក្សា និងផ្លាស់ប្តូរយោបល់មួយដែលមានតុល្យភាព (balanced), គ្រប់ជ្រុងជ្រោយ និងប្រកបដោយបរិយាប័ន្ន (inclusive) ដើម្បីកំណត់ពីការងារអាទិភាពសម្រាប់កម្ពុជា ក្នុងការត្រៀមខ្លួនចាកចេញពីឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច, កំណត់ទិសដៅយុទ្ធសាស្ត្រទៅមុខសម្រាប់ដំណើរអភិវឌ្ឍន៍របស់ខ្លួន ព្រមទាំងត្រៀមខ្លួនក្នុងការចាប់យកកាលានុវត្តភាព និងឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី** និងក្មួយៗទាំងអស់!

៨- ជាការពិតណាស់ កម្ពុជា ត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍ នៃអង្គការសហប្រជាជាតិ ថាបានបំពេញលក្ខន្តិកៈគ្រប់គ្រាន់ក្នុងការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច ជាលើកដំបូងនៅឆ្នាំ២០២១ ពោលគឺ៦ឆ្នាំបន្ទាប់ពីកម្ពុជា បានចាកចេញពីឋានៈជាប្រទេសដែលមានចំណូលទាប។

៩- ត្រង់ចំណុចនេះ ខ្ញុំសូមទាញចំណាប់អារម្មណ៍ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗ អំពីភាពខុសគ្នារវាងឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច និងឋានៈជាប្រទេសដែលមានចំណូលទាប។ ថ្វីត្បិតតែអ្នកបង្កើតគោលនយោបាយ អ្នកវិទ្យាសាស្ត្រសង្គម រួមទាំងសេដ្ឋកិច្ចវិទូ អង្គការអន្តរជាតិ ដូចជា UN, WB, IMF, OECD និយមប្រើពាក្យទាំងពីរ ដើម្បីសំដៅលើប្រទេសកំពុងអភិវឌ្ឍន៍ ប៉ុន្តែសូចនាករដែលប្រើសម្រាប់ការចាត់ថ្នាក់នៃប្រភេទទាំងពីរនេះ គឺមានលក្ខណៈខុសគ្នា។

១០- ជាក់ស្តែង ចំណាត់ថ្នាក់ប្រទេសដែលមានចំណូលទាប ចំណូលមធ្យម ឬចំណូលខ្ពស់ គឺផ្អែកលើចំណូលជាតិសរុប (GNI) ដែលចំណាត់ថ្នាក់នេះត្រូវបានបង្កើតដោយធនាគារពិភពលោក ដើម្បីវាស់វែងកម្រិតនៃការអភិវឌ្ឍរបស់ប្រទេសនីមួយៗ។ ចំណែកចំណាត់ថ្នាក់សម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួចវិញ គឺផ្អែកលើកត្តាចំនួន៣៖ ចំណូលជាតិសរុបក្នុងប្រជាជនម្នាក់ (GNI per capita), ការអភិវឌ្ឍធនធានមនុស្ស (Human Assets), និងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងបរិស្ថាន (Economic and Environmental Vulnerability)។ ប៉ុន្តែ ខ្ញុំសូមមិនលម្អិតទៅលើសូចនាករសម្រាប់កំណត់លើការវាស់វែងនីមួយៗនោះទេ គឺគ្រាន់តែចង់បញ្ជាក់កុំឱ្យមានការភ័ន្តច្រលំថាកម្ពុជាបានចាកចេញពីប្រទេសមានចំណូលទាបកាលពីឆ្នាំ២០១៥ រួចទៅហើយ ហេតុអ្វីបានជាថ្ងៃនេះយើងនិយាយអំពីការត្រៀមខ្លួនក្នុងការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច ទៅវិញ។ ខ្ញុំសង្ឃឹមថា បន្ទាប់ពីបានចូលរួមក្នុងកិច្ចពិភាក្សាថ្ងៃនេះ អ្នកដែលមានវត្តមានក្នុងថ្ងៃនេះ ជាពិសេសក្មួយៗជានិស្សិត ចាប់ពីថ្ងៃនេះទៅនឹងលែងមានការយល់ច្រលំទៅលើការចាត់ថ្នាក់ទាំងពីរប្រភេទនេះទៀត។

**អង្គពិធីជាទីគោរព!**

១១- ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន កំពុងស្ថិតក្នុងរបត់ថ្មីមួយ។ រដ្ឋសភាដែលកើតចេញពីលទ្ធផលនៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌ កាលពីខែកក្កដា ឆ្នាំ២០២៣ កន្លងទៅ បានបង្កើតរដ្ឋាភិបាលដែលជាអន្តរកាលនៃអ្នកបន្តវេន ពោរពេញទៅដោយសមត្ថភាព ឆន្ទៈ និងភាពស្វាហាប់ក្នុងការបន្តនូវសមិទ្ធផលចាស់ និងបង្កើនសមិទ្ធផលថ្មី។

ដំណើររបស់កម្ពុជា ក្នុងការចាកចេញពីឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួចនេះ គឺជាវិវត្តជាក់ស្តែង ដែលថ្នាក់ដឹកនាំជំនាន់ក្រោយត្រូវខិតខំប្រឹងប្រែងបំពេញបន្ថែមលើសមិទ្ធផលដែលថ្នាក់ដឹកនាំជំនាន់មុនបានកសាង។

១២- **ការចាកចេញពីឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួចនាពេលខាងមុខនេះ គឺជាដំណើរទៅមុខមួយជំហានទៀត ឆ្ពោះទៅសម្រេចបានចក្ខុវិស័យ២០៣០ និង២០៥០ របស់កម្ពុជា។**

១៣- បន្ទាប់ពីទទួលបានលទ្ធផលជោគជ័យពីការវាយតម្លៃប្រចាំបីឆ្នាំជាលើកទីពីរ (2nd Triennial Review) កាលពីដើមខែមីនា កម្ពុជានឹងកំណត់អាទិភាពទិសដៅទៅមុខសម្រាប់ខ្លួនឯង។ ជាការពិតណាស់ ប្រមុខរាជរដ្ឋាភិបាលគឺជាអ្នកជួរមុខក្នុងការដឹកនាំ ប៉ុន្តែភាពជោគជ័យពេញលេញតម្រូវឱ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធសំខាន់ៗ ដូចជា ដៃគូអភិវឌ្ឍន៍ ស្ថាប័ននិងវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងវិស័យឯកជន។ វេទិកានេះគឺជាសក្ខីភាពឆ្លុះបញ្ចាំងពីការចូលរួមរបស់ភាគីពាក់ព័ន្ធ។ ចំពោះថាតើអ្វីគួរតែជាទិសដៅទៅមុខសម្រាប់កម្ពុជានៅក្នុងពេលនេះ ខ្ញុំនឹងប្រគល់វេទិកាជូនវាគ្មិនទាំងបីរូប ធ្វើការបកស្រាយជូននាពេលបន្តិចទៀត។

១៤- មុននឹងបញ្ចប់ ខ្ញុំសូមអនុញ្ញាតថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី សិស្សនិស្សិត និងភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួមកិច្ចពិភាក្សាតុមូលនាសៀលនេះ ហើយខ្ញុំក៏សូមលើកទឹកចិត្តឱ្យមានការចូលរួមឱ្យបានផុលផុស នៅក្នុងវគ្គសំណួរ និងចម្លើយ ពីព្រោះគោលបំណងរបស់យើងថ្ងៃនេះ គឺមិនមែនសួរ ឆ្លើយទេ គឺចង់ជំរុញឱ្យមានការចូលរួមមតិយោបល់ពីគ្រប់មជ្ឈដ្ឋាន ទើបបានជាយើងរៀបចំជាទម្រង់កិច្ចពិភាក្សាបែបនេះ។

ខ្ញុំសូមប្រកាសបើក កិច្ចពិភាក្សាតុមូល ស្តីពី **«ការវាយតម្លៃលើការចាកចេញពីឋានៈជាប្រទេសដែលមានការអភិវឌ្ឍតិចតួចរបស់កម្ពុជា»** ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***

## II. សម្រង់ខ្លឹមសារកិច្ចពិភាក្សាតុមូល៖ «ការវាយតម្លៃការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច»

### ❖ ដំណើរការនៃចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច

យោងតាមអង្គការសហប្រជាជាតិ ប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ត្រូវបានកំណត់ថាជាប្រទេសដែលមានប្រាក់ចំណូលទាប ងាយរងគ្រោះដោយសារការប៉ះទង្គិចផ្នែកសេដ្ឋកិច្ច និងបរិស្ថាន និងមានធនធានមនុស្សមិនគ្រប់គ្រាន់។ បន្ទាប់ពីការចាកចេញពីចំណាត់ថ្នាក់របស់ប្រទេសប៊ូតាន នៅឆ្នាំ២០២៣ បច្ចុប្បន្នមានប្រទេសចំនួន ៤៥ ជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលប្រទេសទាំងនោះ មានចំនួនប្រជាជនប្រហែល មួយពាន់លាននាក់ ប៉ុន្តែផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក មានចំនួនតិចជាង ២% និងពាណិជ្ជកម្មកសល គឺតិចជាង ១%។

ក្នុងការចាត់ថ្នាក់ជាប្រទេសឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច នៃអង្គការសហប្រជាជាតិ ធ្វើការពិនិត្យលើលក្ខណៈវិនិច្ឆ័យចំនួន ៣៖ ១) ប្រាក់ចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់ (GNI Per Capita), ធនធានមនុស្ស (Human Asset Index) និងភាពងាយរងគ្រោះខាងសេដ្ឋកិច្ច និងបរិស្ថាន (Environmental Vulnerability Index)។

ដើម្បីចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួច ប្រទេសនីមួយៗ ត្រូវបំពេញតាមលក្ខខណ្ឌទាំង ៣ ឬយ៉ាងតិចចំនួន ២ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំង ៣ ឬសម្រេចឱ្យបានទ្វេដងនៃលក្ខខណ្ឌវិនិច្ឆ័យនៃប្រាក់ចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់ ក្នុងការវាយតម្លៃជាប្រៀងរាលបីឆ្នាំម្តង។ ទោះបីជាការវាយតម្លៃថាជាប្រទេសអភិវឌ្ឍន៍តិចតួច ត្រូវបានវាយតម្លៃ ១ដង និងចូលជាធរមានភ្លាម ការចាកចេញមានរយៈពេលអន្តរកាល ៣ឆ្នាំ ដែលក្នុងរយៈពេលអន្តរកាលនោះ អង្គការសហប្រជាជាតិ ផ្តល់ការគាំទ្រលើការចាកចេញ តាមរយៈការបង្កើត «**យុទ្ធសាស្ត្រត្រៀមខ្លួនចាកចេញដោយរលូន**» ជាយន្តការឆ្លើយតប និងដោះស្រាយបញ្ហាប្រឈមដែលអាចកើតមានឡើង និងទាញយកអត្ថប្រយោជន៍ពីកាលានុវត្តភាពថ្មី ក្នុងអំឡុងរយៈពេលអន្តរកាល។

ការចាកចេញពីចំណាត់ថ្នាក់ប្រទេសអភិវឌ្ឍន៍តិចតួច គឺជាដំណើរការដែលមានច្រើនដំណាក់កាល និងមានរយៈពេលវែង។ ដំណើរការនេះ តម្រូវឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន ជាពិសេសរដ្ឋាភិបាល ដែលជាម្ចាស់ប្រទេស និងជាតួអង្គសំខាន់ក្នុងការដាក់ចេញ និងអនុវត្តគោលនយោបាយ និងស្ថាប័នដៃគូអន្តរជាតិដែលជាអ្នកផ្តល់ការគាំទ្រលើទិដ្ឋភាពបច្ចេកទេស និងហិរញ្ញវត្ថុនានា។ នៅក្នុងដំណើរការចាកចេញពីចំណាត់ថ្នាក់ប្រទេសអភិវឌ្ឍន៍តិចតួច គឺជាការវាយតម្លៃឯករាជ្យរបស់គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍ ដែលមិនតម្រូវឱ្យមានការសុំការអនុញ្ញាតពីរដ្ឋាភិបាល ប៉ុន្តែនៅក្នុងនីតិវិធីនៃការចាកចេញ គឺមានការធ្វើការពិភាក្សាពិគ្រោះយោបល់ យ៉ាងល្អិតល្អន់ និងគ្រប់ជ្រុងជ្រោយរវាងរដ្ឋាភិបាល និងអង្គការដៃគូអន្តរជាតិ ដើម្បីធានាថាទស្សនវិស័យ សំណូមពរ និងធាតុចូលពីភាគីរដ្ឋាភិបាល ត្រូវបានពិចារណា នៅក្នុងដំណើរការចាកចេញនេះ។ ជាឧទាហរណ៍ជាក់ស្តែង គួរបញ្ជាក់ផងដែរថា នៅក្នុងដំណើរការនៃការវាយតម្លៃសម្រាប់ការចាកចេញពីចំណាត់ថ្នាក់ប្រទេសអភិវឌ្ឍន៍តិចតួចនេះ បណ្តាប្រទេស LDC ឆ្លងកាត់ការវាយតម្លៃដោយស្មើភាព និងយុត្តិធម៌ ជាមួយនឹងការអនុវត្តនីតិវិធីប្រកបដោយភាពបត់បែន ជាពិសេសសម្រាប់ប្រទេសដែលឈានដល់កម្រិតនៃការចាកចេញ ដើម្បីធានាបាននូវការចាកចេញប្រកបដោយភាពរលូន និងប្រាកដថា ប្រទេសទាំងនោះមិនវិលត្រឡប់មកក្នុងកម្រិតអភិវឌ្ឍន៍តិចតួចវិញម្តងទៀត។

### ❖ ដំណើរការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា

ការវាយតម្លៃបឋមរបស់អង្គការសហប្រជាជាតិសម្រាប់ការពិនិត្យឡើងវិញរយៈពេលបីឆ្នាំ ក្នុងឆ្នាំ២០២៤ បានផ្តល់សញ្ញាវិជ្ជមានដល់កម្ពុជាក្នុងការចាកចេញពីប្រទេសអភិវឌ្ឍតិចតួច ក្នុងរយៈពេលអន្តរកាល ៥ឆ្នាំ ជាមួយនឹង ប្រាក់ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ៗ ចំនួន ១.៥៩០ដុល្លារ លើសពីកម្រិតដែលបានកំណត់ត្រឹមតែ ១.៣០៦ដុល្លារ។ កម្ពុជា ក៏ទទួលបានពិន្ទុល្អចំនួន ៧៧,៨ លើសន្ទស្សន៍ទ្រព្យសម្បត្តិ (HAI) ដែលលើសពីកម្រិត ៦៦ ឬខ្ពស់ជាងនេះ ព្រមទាំងវឌ្ឍនភាពល្អក្នុងសន្ទស្សន៍សេដ្ឋកិច្ច និងបរិស្ថាន (EVI) ផងដែរជាមួយនឹងពិន្ទុ ២៤,១។ (សូមមើលតារាង ទី១)[1]

[1] United Nations. (2024). *Committee for Development Policy Report on the twenty-sixth session (4–8 March 2024): Economic and Social Council.* Official Records, 2024 Supplement No. 13

*តារាងទី១៖ ទស្សនវិស័យនៃការចាកចេញពី LDC របស់កម្ពុជា (២០០៩-២០២៤)*

| ឆ្នាំនៃការវាយតម្លៃ | | ២០០៩ | ២០១២ | ២០១៥ | ២០១៨ | ២០២១ | ២០២៤ |
|---|---|---|---|---|---|---|---|
| ចំណូលជាតិសរុបក្នុងប្រជាជនម្នាក់ (GNI) (ដុល្លារអាមេរិក) | | ១.០៨៦ | ១.១៩០ | ១.២៤២ | ១.២៣០ | ១.២២២ | ១.៣០៦ |
| ចំណូលសរុបរបស់ប្រជាជនកម្ពុជា (ដុល្លារអាមេរិក) | | ៤៩០ | ៧០៧ | ៨៥២ | ១.៩៧៥ | ១.៣៧៧ | ១.៥៩០ |
| ប្រៀបធៀបនឹងកម្រិត | | -៥៩៦ | -៤៨៣ | -៣៩០ | -១៥៥ | +១៥៥ | +២៨៤ |
| | | *មិនជាប់* | *មិនជាប់* | *មិនជាប់* | *មិនជាប់* | ***ជាប់*** | ***ជាប់*** |
| ការអភិវឌ្ឍន៍ធនធានមនុស្ស | | ៦៦ | ៦៦ | ៦៦ | ៦៦ | ៦៦ | ៦៦ |
| HAI របស់កម្ពុជា | | ៥៨ | ៥៨ | ៦៧ | ៦៩ | ៧៤,៣ | ៧៧,៨ |
| ប្រៀបធៀបនឹងកម្រិត | | -៨ | -៨ | +១ | +៣ | +៨,៣ | +១១,៨ |
| | | *មិនជាប់* | *មិនជាប់* | *មិនជាប់* | *មិនជាប់* | ***ជាប់*** | ***ជាប់*** |
| ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងបរិស្ថាន | | ៣៨ | ៣២ | ៣២ | ៣២ | ៣២ | ៣២ |
| EVI របស់កម្ពុជា | | ៥៦ | ៥០ | ៣៨ | ៣៥ | ៣០,៦ | ២៤,១ |
| ប្រៀបធៀបនឹងកម្រិត | | -១៨ | -១៨ | -៦ | -៣ | +២,៦ | +៧,៩ |
| | | *មិនជាប់* | *មិនជាប់* | *មិនជាប់* | *មិនជាប់* | ***ជាប់*** | ***ជាប់*** |

### ❖ អត្ថប្រយោជន៍ និងយន្តការគាំទ្រចំពោះកម្ពុជា

ចាប់តាំងពីការដាក់បញ្ចូលក្នុងការចាត់ថ្នាក់ជាប្រទេសអភិវឌ្ឍន៍តិចតួចក្នុងឆ្នាំ១៩៩១ កម្ពុជា ទទួលបានការគាំទ្រ តាមរយៈវិធានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុផ្សេងៗ ដែលជាអត្ថប្រយោជន៍ដ៏សំខាន់ ពីដៃគូសហប្រតិបត្តិការទ្វេភាគី អង្គការពហុភាគី ដូចជាអង្គការពាណិជ្ជកម្មពិភពលោក អង្គការសហប្រជាជាតិ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងបណ្តាស្ថាប័នអន្តរជាតិនានា។

ក្នុងទិដ្ឋភាពពាណិជ្ជកម្ម ដៃគូអភិវឌ្ឍន៍ បានផ្តល់ការគាំទ្រដល់កម្ពុជា ដើម្បីជំរុញភាពប្រកួតប្រជែង និងធ្វើសមាហរណកម្មទៅក្នុងទីផ្សារអន្តរជាតិ តាមរយៈផ្តល់ការអនុគ្រោះពន្ធពាណិជ្ជកម្ម។ សហភាពអឺរ៉ុប គឺជាដៃគូដ៏សំខាន់ ដែលបានគាំទ្រកម្ពុជា ក្នុងទិដ្ឋភាពពាណិជ្ជកម្ម។ ការគាំទ្រទាំងនោះរួមមាន ប្រព័ន្ធអនុគ្រោះពន្ធទំនិញគ្រប់ប្រភេទលើកលែងតែអាវុធ (Everything but Arms/EBA) ដែលបានផ្តល់ការអនុគ្រោះពន្ធ និងការកំណត់កូតាសមសម្រាប់គ្រប់ការនាំចូលផលិតផលពីកម្ពុជា និងបណ្តាប្រទេស LDC ដទៃទៀត ដោយលើកលែងតែគ្រឿងសព្វាវុធ។

ក្នុងនាមជាប្រទេសហត្ថលេខី កម្ពុជាបានទទួលអត្ថប្រយោជន៍ពីការជំរុញកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈកិច្ចព្រមព្រៀង ស្ដីពីការជំរុញពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក។ អាមេរិក គឺជាទីផ្សារដ៏សំខាន់មួយរបស់កម្ពុជា តាមរយៈពាណិជ្ជកម្មទ្វេភាគី ប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌប្រព័ន្ធអនុគ្រោះពន្ធទូទៅ (Generalized System of Preferences) ដែលផ្ដល់ការអនុគ្រោះពន្ធ និងការកំណត់ចំនួនកូតាស្មើៗគ្នាលើមុខទំនិញជាក់លាក់ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ នាំចេញផលិតផលមកកាន់ទីផ្សារអាមេរិក។

បន្ថែមពីលើនេះ កម្ពុជា ទទួលបានការគាំទ្រជាច្រើន តាមរយៈវិធានការពិសេសអន្តរជាតិ ពិសេសក្នុងផ្នែកពាណិជ្ជកម្ម ហិរញ្ញប្បទានសហប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការបច្ចេកទេស។ ភាពអនុគ្រោះក្នុងផ្នែកពាណិជ្ជកម្មក្នុងក្របខ័ណ្ឌអន្តរជាតិនេះ ត្រូវបានផ្ដល់តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា (Trade Related Aspects of Intellectual Property Right) និងកិច្ចព្រមព្រៀង ស្ដីពីវិធានការសម្រាប់ការវិនិយោគ ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម (Agreement on Trade-Related Investment Measures)។ កម្ពុជា ក៏ទទួលបានការគាំទ្រ តាមរយៈផែនការសកម្មភាពសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច (LDC Programme of Action) ដែលបានអនុម័តក្នុងឆ្នាំ២០១១ ដែលផ្ដោតសំខាន់លើការពង្រឹងសមត្ថភាពផ្នែកផលិតកម្ម និងកំណែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច រួមមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍមូលធនមនុស្ស និងមូលធនសង្គម។

- **បញ្ហាប្រឈមមកលើកម្ពុជា ក្រោយការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួច**[2]

នៅពេលចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច កម្ពុជា ប្រឈមនឹងការបាត់បង់ការទទួលផលពីការនាំចេញមិនយកពន្ធ និងមិនកំណត់កូតា (Duty-Free, Quota-Free) ដែលនឹងជះឥទ្ធិពលដល់ការនាំចេញសម្លៀកបំពាក់។ បន្ទាប់ពីការចាកចេញ ប្រព័ន្ធអនុគ្រោះពន្ធទូទៅ នឹងត្រូវផ្លាស់ប្ដូរទៅជាប្រព័ន្ធមួយផ្សេង ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងប្រព័ន្ធ GSPs ដែលកំពុងអនុវត្តនៅបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍។ ប្រព័ន្ធ GSP+ ផ្ដល់ភាពអនុគ្រោះស្រដៀងនឹងប្រព័ន្ធ EBA ដែរ ប៉ុន្តែតម្រូវឱ្យប្រទេសទទួលផល ចុះហត្ថលេខាលើការប្ដេជ្ញាលើកកម្ពស់សិទ្ធិមនុស្ស និងបទដ្ឋានការងារ។ ម្យ៉ាងវិញ កម្ពុជានឹងប្រឈមមុខនឹងការបាត់បង់ការអនុគ្រោះពាណិជ្ជកម្ម។ សម្រាប់ការនាំចេញសម្លៀកបំពាក់ វាយនភ័ណ្ឌ ស្បែកជើង និងទំនិញធ្វើដំណើរ ពន្ធជាមធ្យមកើនឡើងពី 0% ដល់ ៨,៨% ក្រោម EBA និង GSP+ របស់សហភាពអឺរ៉ុប និង១១,៥% ក្រោមអត្រាពន្ធគយនាំចូលសម្រាប់ប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត (Most-favoured-Nation)។ សម្រាប់ការនាំចេញកង់ និងទោចក្រយានយន្តផ្សេងៗ ពន្ធនឹងកើនដល់ ១០,១% ក្រោម GSP និង ១៤,៥% ក្រោម MFN។ ចំណែកការនាំចេញរបស់កម្ពុជាទៅកាន់ប្រទេសកាណាដា ក្រោយការចាកចេញពីឋានៈជា LDC ប្រឈមនឹងការដំឡើងពន្ធរហូតដល់ ១៦,១% ក្រោម GSP/GPT និង ១៦,៤% ក្រោមអត្រា MFN សម្រាប់សម្លៀកបំពាក់ វាយនភណ្ឌ

[2] ទិន្នន័យនៅក្នុងផ្នែកនេះ ដកស្រង់ចេញពីប្រសាសន៍របស់វាគ្មិន និងជាការដកស្រង់ពីរបាយការណ៍ UNDP's draft report on Cambodia's graduation from LDC status – Preparedness and Smooth Transition Strategy (Sep 2023).

ស្បែកជើង និងទំនិញធ្វើដំណើរ និងពន្ធទៅលើការនាំចេញកង់ចំនួន ៨,៥% ក្រោម GSP និង ១៣,០% ក្រោម MFN។

ការនាំចេញរបស់កម្ពុជា នឹងត្រូវគោរពតាមវិធានដើមកំណើតទំនិញដ៏តឹងរ៉ឹងសម្រាប់ការនាំចេញ ទៅកាន់ទីផ្សារសហភាពអឺរ៉ុប និងចក្រភពអង់គ្លេស ដូចជាការផ្លាស់ប្តូរពីរដង (Double transformation) សម្រាប់វាយនភណ្ឌ និងសម្លៀកបំពាក់ និងតម្លៃបន្ថែមក្នុងស្រុកអប្បបរមា ៥០% សម្រាប់ទំនិញផ្សេងៗ ជាជាងការបំប្លែងតែមួយ និងតម្លៃបន្ថែមអប្បបរមា ៣០%។ ប្រទេសដែលចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច ជាគោលការណ៍ អាចអនុវត្តចំពោះការរៀបចំពិសេសរបស់សហភាពអឺរ៉ុប សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងអភិបាលកិច្ចល្អ (GSP+) ដែលផ្តល់នូវការចូលប្រើប្រាស់ដោយឥតគិតថ្លៃដល់ ៦៦% នៃបន្ទាត់ពន្ធរបស់សហភាពអឺរ៉ុប (បន្ថែមពីលើពន្ធ MFN សូន្យ)។ ប្រសិនបើកម្ពុជា មិនមានគ្រប់លក្ខខណ្ឌក្នុងការទទួលផលពី GSP+ និងមិនមានការចរចាបន្ថែមទៅប្រព័ន្ធនេះ ផលិតផលរបស់កម្ពុជា នាំចូលទៅក្នុងទីផ្សារសហភាពអឺរ៉ុប នឹងចូលក្នុងលក្ខខណ្ឌ GSP ឬ MFN ធម្មតា។ កម្ពុជា ក៏នឹងតម្រូវឱ្យប្រកាន់ខ្ជាប់នូវវិធានដើមកំណើតទំនិញដ៏តឹងរ៉ឹងបន្ថែម ជាមួយនឹងការនាំចូលមានកម្រិតតិចជាង ៤០% ផ្ទុយទៅនឹង ៦០% សម្រាប់ LDCs សម្រាប់ទីផ្សារកាណាដា។ ផលិតផលដែលមិនអនុលោមតាមវិធានដើមកំណើតទំនិញ នឹងត្រូវស្ថិតនៅក្រោមអត្រាពន្ធ MFN កំណត់ដោយប្រទេសកាណាដា។

# សេចក្ដីសន្និដ្ឋាន

## ដំណើរការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច ជាជំហានចាំបាច់ ក្នុងការឈានទៅសម្រេចបាន ចក្ខុវិស័យអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០៣០ និង២០៥០

ការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួច គឺជាសមិទ្ធផលដ៏គួរឱ្យកោតសរសើរមួយនៃការអភិវឌ្ឍរបស់កម្ពុជា។ ការណ៍នេះ បង្ហាញពីការដាក់ចេញគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដែលនាំមកនូវការសម្រេចបានកំណើនប្រចាំឆ្នាំ ៧%, ភាពរីកចម្រើននៃសង្គមកម្ពុជាដ៏រស់រវើក និងទំនើប ជាពិសេសការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន។ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំរបស់កម្ពុជា ក្នុងការសម្រេចបានចក្ខុវិស័យកម្ពុជាជាឋានៈ**ប្រទេសមានប្រាក់ចំណូលកម្រិតខ្ពស់ ឆ្នាំ២០៥០**។ បន្ថែមពីលើយុទ្ធសាស្ត្របញ្ចកោណ រាជរដ្ឋាភិបាល បាននិងកំពុងរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០២៤-២០២៨ ដែលនឹងជាយន្តការមួយ ដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងការអភិវឌ្ឍជាតិលើគ្រប់វិស័យនៃអាទិភាពនានាក្នុងស្មារតីនៃការថែរក្សាសមិទ្ធផលចាស់ និងបង្កើនសមិទ្ធផលថ្មីបន្ថែម។



**អនុសាសន៍ ទី១** កម្ពុជា អាចប្រែក្លាយបញ្ហាទៅជាឱកាស បើទោះបីជាបាត់បង់ EBA ជំនួយមួយចំនួន និងប្រព័ន្ធអនុគ្រោះពន្ធ ការនាំចេញនៅតែបន្ត ចំណែកឯរោងចក្រក៏នៅមាន។ ដូច្នេះ កម្ពុជាអាចប្រែក្លាយបញ្ហានេះ ទៅជាឱកាសដោយការធ្វើនវានុវត្តន៍ផលិតភាព និងការនាំចេញ។

**អនុសាសន៍ ទី២** ធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើនភាពប្រកួតប្រជែង ដែលជាមូលដ្ឋាននៃការគាំទ្រកំណើន ប្រកបដោយចីរភាព និងភាពធន់ តាមរយៈការអភិវឌ្ឍវិស័យគន្លឹះ និងការបន្តបង្កើតប្រភពថ្មីនៃទីផ្សារ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច។





**អនុសាសន៍ ទី៣** ការអភិវឌ្ឍមូលធនមនុស្ស ជាកត្តាសំខាន់ដែលរួមចំណែកដល់ការអភិវឌ្ឍជាតិ និងកំណើនសេដ្ឋកិច្ច សំដៅធានាបាននូវចីរភាពកំណើនរយៈពេលវែង។

## ❖ អនុសាសន៍

ការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួច គឺជាសមិទ្ធផលដ៏គួរឱ្យកោតសរសើរមួយនៃវឌ្ឍនភាពនៃការអភិវឌ្ឍរបស់កម្ពុជា។ ការណ៍នេះ បង្ហាញពីការដាក់ចេញគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដែលនាំមកនូវការសម្រេចបានកំណើនប្រចាំឆ្នាំក្នុងរង្វង់ ៧%, ភាពរីកចម្រើននៃសង្គមកម្ពុជាដ៏រស់រវើក និងទំនើប ជាពិសេសការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន។ បន្ថែមពីនេះ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំរបស់កម្ពុជា ក្នុងការឈានទៅសម្រេចបាន ចក្ខុវិស័យកម្ពុជា ជាឋានៈប្រទេសមានប្រាក់ចំណូលកម្រិតខ្ពស់ ឆ្នាំ២០៥០។ បន្ថែមពីលើយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ រាជរដ្ឋាភិបាល បាននិងកំពុងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០២៤-២០២៨ ដែលនឹងជាយន្តការមួយ ដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងការអភិវឌ្ឍជាតិគ្រប់វិស័យអាទិភាព ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

ការណ៍នេះ បង្ហាញពីសមិទ្ធផលដ៏ធំធេងនៃដំណើរការអភិវឌ្ឍជាតិពិតប្រាកដ ប៉ុន្តែរាល់ការបោះជំហានទៅមុខ រមែងមានការផ្លាស់ប្តូរ និងបញ្ហាប្រឈមនានា ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ល្អិតល្អន់ ពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីបន្តរក្សាសមិទ្ធផលចាស់ និងបង្កើនសមិទ្ធផលថ្មី។ ដកស្រង់ចេញពីកម្មវិធីកិច្ចពិភាក្សាតុមូលក្រោមប្រធានបទ «**ការវាយតម្លៃជុំវិញការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា**» នេះ វាគ្មិនពិភាក្សា បានបញ្ចេញទស្សនៈជាធាតុចូល និងផ្លាស់ប្តូរយោបល់មួយដែលមានតុល្យភាពគ្រប់ជ្រុងជ្រោយ និងប្រកបដោយបរិយាប័ន្ននៃការងារអាទិភាពសម្រាប់កម្ពុជា ក្នុងការត្រៀមខ្លួនចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច, កំណត់ទិសដៅយុទ្ធសាស្ត្រទៅមុខសម្រាប់ដំណើរអភិវឌ្ឍន៍របស់ខ្លួន ព្រមទាំងត្រៀមខ្លួនក្នុងការចាប់យកកាលានុវត្តភាព និងឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា។

១- កម្ពុជា នឹងប្រឈមនឹងការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្មមួយចំនួន ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការនាំចេញពាណិជ្ជកម្ម ក្នុងនោះការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធការនាំចូលទំនិញគ្រប់ប្រភេទលើកលែងតែអាវុធ (EBA) របស់សហភាពអឺរ៉ុប ប៉ុន្តែកម្ពុជា បានឆ្លងផុតបញ្ហានេះម្តងរួចមកហើយកាលពីឆ្នាំ២០១៩។ យោងតាមបទពិសោធន៍នោះ បើទោះបីជា កម្ពុជាប្រឈមនឹងការបាត់បង់ EBA ការនាំចេញនៅតែបន្ត ចំណែកឯរោងចក្រក៏នៅដំណើរការផលិតកម្ម។ ដូចច្នេះ កម្ពុជាអាចប្រែក្លាយបញ្ហានេះ ទៅជាកាលានុវត្តភាព ដោយការបន្តជំរុញនវានុវត្តន៍ផលិតភាព និងការនាំចេញ។

២- ធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើនភាពប្រកួតប្រជែង ដែលជាមូលដ្ឋាននៃការគាំទ្រកំណើន ប្រកបដោយចីរភាព និងភាពធន់ តាមរយៈការអភិវឌ្ឍវិស័យគន្លឹះ និងការបន្តបង្កើតប្រភពថ្មីនៃទីផ្សារ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច។

៣- ការអភិវឌ្ឍមូលធនមនុស្ស ជាកត្តាសំខាន់ដែលរួមចំណែកដល់ការអភិវឌ្ឍជាតិ និងកំណើនសេដ្ឋកិច្ច។ ក្នុងន័យនេះ បញ្ចកោណទី១ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ រាជរដ្ឋាភិបាល បានផ្ដល់អាទិភាពសំខាន់លើការអភិវឌ្ឍមូលធនមនុស្ស សំដៅធានាបាននូវចីរភាពកំណើនរយៈពេលវែង។ នៅពេលដែលមូលធនមនុស្ស មានសមត្ថភាពខ្ពស់ មានជំនាញ និងវិជ្ជាជីវៈច្បាស់លាស់ វាជាកម្លាំងចលករដ៏សំខាន់ ក្នុងការចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។

៤- ការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច មានអត្ថន័យសំខាន់សម្រាប់ប្រជាជនម្នាក់ៗ។ ការចាកចេញពីចំណាត់ថ្នាក់នេះ បានបង្ហាញពីភាពធន់ និងសន្ទុះនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍគ្រប់វិស័យនៃអាទិភាព។ លើសពីនេះ ប្រទេសកម្ពុជា ធ្លាប់ឆ្លងកាត់សង្គ្រាម ដែលធ្លាក់ដល់ចំណុចសូន្យ ដូចនេះការចាកចេញពីភាពក្រីក្រ មានអត្ថន័យធំធេង ដែលគឺជាមោទនភាពជាតិ។

៥- ប្រទេសកម្ពុជាអាចកំណត់ទីតាំងខ្លួនជាគោលដៅទាក់ទាញសម្រាប់ការវិនិយោគក្នុងឧស្សាហកម្ម ដែលជំរុញដោយបច្ចេកវិទ្យាដែលមានតម្លៃខ្ពស់។ យុទ្ធសាស្ត្រនេះ នឹងពង្រឹងការធ្វើពិពិធកម្មសេដ្ឋកិច្ច និងរួមចំណែកដល់ការបង្កើតឱកាសការងារ ពង្រីកពាណិជ្ជកម្ម និងការធ្វើពិពិធកម្មវិស័យឧស្សាហកម្ម ព្រមទាំងឈានទៅសម្រេចបានកំណើនប្រកបដោយភាពធន់ ចីរភាព និងមានបរិយាប័ន្ន។

## III. សុន្ទរកថាបិទ

**ឯកឧត្តម សុខន តារាពី**
**នាយករង មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា**

១- សូមគោរព៖

- **ឯកឧត្តមបណ្ឌិត អ៊ុន យាង,** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- **បណ្ឌិត យន់ គា**, នាយករង វិទ្យាស្ថានសិក្សាអន្តរជាតិ និងគោលនយោបាយសាធារណៈ
- **បណ្ឌិត គី សេរីវឌ្ឍន៍**, ប្រធាន មជ្ឈមណ្ឌលសិក្សាចិននៃរាជបណ្ឌិត្យសភាកម្ពុជា
- **បណ្ឌិត អ៊ួច ចាន់ដារ៉ានី**, សេដ្ឋកិច្ចវិទូ ប្រចាំការិយាល័យអង្គការសហប្រជាជាតិកម្ពុជា
- **ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយស និងប្អូនៗនិស្សិតជាទីមេត្រី!**

២- ថ្ងៃនេះ ដោយទទួលបានការចាត់តាំងពី **ឯកឧត្តមនាយកប្រតិបត្តិ** ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលមានឱកាសថ្លែងនៅក្នុងកិច្ចពិភាក្សាតុមូល ក្រោមប្រធានបទ **«ការវាយតម្លៃលើការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា»**។

៣- មុននឹងចាប់ផ្តើម ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វាគ្មិនទាំងបីរូប ដែលបានចូលរួមចែករំលែកចំណេះដឹង និងការយល់ឃើញរបស់ខ្លួនជូនដល់អង្គពិធី ជាពិសេស បណ្ឌិត យន់ គា ដែលជាអ្នកសម្របសម្រួលដ៏ប៉ិនប្រសប់នៅក្នុងកិច្ចពិភាក្សារបស់យើងនារសៀលនេះ។

៤- ជាកិច្ចចាប់ផ្តើម ខ្ញុំសូមធ្វើការសរុបឡើងវិញនូវអ្វីដែលជាការពិភាក្សាយ៉ាងស៊ីជម្រៅ និងសកម្មដែលខ្ញុំបានកត់សម្គាល់ដោយផ្ទាល់ ចំនួន បី ចំណុច។

៥- ខ្ញុំសូមគាំទ្រចំពោះការលើកឡើងរបស់ ឯកឧត្តមបណ្ឌិត អ៊ុន យាង អំពីសារៈសំខាន់នៃវេទិកានេះ ដែលទទួលបានការចូលរួមពីផ្នែករាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងស្ថាប័នស្រាវជ្រាវ។ បើទោះបីជានេះជាវេទិកាដំបូង។ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា មានសុទិដ្ឋិនិយម និងទទួលបានការចាប់អារម្មណ៍ពីប្រធានបទនេះសម្រាប់ឆ្នាំនេះ និងតទៅមុខ។

៦- ពិតណាស់ ការពិភាក្សានារសៀលនេះ គឺមានគោលបំណងចម្បងក្នុងការលើកកម្ពស់ការយល់ដឹងឱ្យបានកាន់តែទូលំទូលាយជុំវិញការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច ដូចជាការយល់ច្រលំរវាងប្រទេសមានចំណូលទាប និងប្រទេសមានការអភិវឌ្ឍន៍តិចតួច។ មួយវិញទៀត ការពិភាក្សានេះ គឺមិនមែនជាការបំភ័យ (ដូចដែល **ឯកឧត្តម គី សេរីវឌ្ឍន៍** បានលើកឡើងពាក់ព័ន្ធ នឹងករណី EBA)។ យើងគួរតែគិតក្នុងន័យវិជ្ជមានមកវិញ ថាអនុញ្ញាតឱ្យចាកចេញពី LDC នេះ មិនមែនចេះតែបាននោះទេ លុះត្រាតែយើងបានបំពេញនូវលក្ខខណ្ឌដែលបញ្ជាក់ថាយើងអាចមានភាពរឹងមាំទាំងសេដ្ឋកិច្ច សង្គម និងជាពិសេស ធនធានមនុស្ស ជាដើម។

៧- ប្រែក្លាយបញ្ហាប្រឈម ទៅជាកាលានុវត្តភាព ហើយពេលនេះគឺជាពេលវេលាមាស (Golden Time)។ ហេតុអ្វីបានជាខ្ញុំថាពេលនេះជា ពេលវេលាមាស? គឺបើយើងចាប់ផ្តើមពីពេលនេះ យើងអាចតម្រង់ទិសយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍របស់យើង ឱ្យមានភាពស៊ីសង្វាក់គ្នា (synergized) ក្នុងទិសដៅតែមួយ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការអនុវត្ត និងប្រើប្រាស់ធនធនថវិកា (មានន័យថាចាយលុយមួយកញ្ចប់ដើម្បីសម្រេចបានគោលដៅ ២-៣)។

៨- ការអភិវឌ្ឍ និងចីរភាព ដើរទន្ទឹមគ្នា។ ចីរភាពគឺរាប់បញ្ចូលទាំងការរក្សាបានចីរភាពនៃការអភិវឌ្ឍ និងចីរភាពបរិស្ថាន ព្រមទាំងសារៈសំខាន់នៃសន្តិភាព និងគោលនយោបាយការបរទេស។

៩- ការចូលរួមរបស់ភាគីពាក់ព័ន្ធត្រូវតែជាកត្តាស្នូលក្នុងការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួច។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

១០- ពិតណាស់ នេះគឺជាពេលវេលាដ៏សំខាន់មួយដែលនឹងកំណត់ជោគវាសនារបស់កម្ពុជា ក្នុងរយៈពេលបីឆ្នាំទៅមុខ។ ពេលវេលាយើងមានខ្លី ប៉ុន្តែមានការងារច្រើនដែលត្រូវធ្វើ។

១១- ដំណើរមួយពិតជាមិនមានភាពងាយស្រួលនោះទេ។ ជាក់ស្តែង ចាប់តាំងពីឆ្នាំ១៩៧១ ដែលអង្គការសហប្រជាជាតិបានបង្កើតចំណាត់ថ្នាក់ប្រទេសដែលមានការអភិវឌ្ឍតិចតួចមក មានតែប្រទេសចំនួន៧ប៉ុណ្ណោះ បានចាកចេញពីឋានៈនេះ (ចុងក្រោយគេគឺប្រទេសប៊ូតង់ ដែលបានចាកចេញពីឋានៈនេះ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣)។ ហើយបច្ចុប្បន្ន មានប្រទេសចំនួន៤៥ទៀត ដែលកំពុងស្ថិតនៅក្នុងការចាត់ថ្នាក់នេះនៅឡើយ។ លើសពីនេះ ក៏ប្រទេសមួយចំនួនដែលត្រៀមខ្លួនចាកចេញពីឋានៈត្រូវបានពន្យាពេលដោយសារបញ្ហានយោបាយផ្ទៃក្នុង (មីយ៉ាន់ម៉ា) ហើយក៏មានប្រទេសផ្សេងទៀតដែលបំពេញលក្ខន្តិកៈគ្រប់គ្រាន់នៅក្នុងការវាយតម្លៃមុន ប៉ុន្តែឃើញថាមានការដើរថយក្រោយទៅវិញ (ទីម័រខាងកើត និងសំប៊ី)។ ប្រាកដណាស់ យើងមិនចង់ឱ្យកម្ពុជា ជួបវាសនាដូចប្រទេសទាំងនេះនោះទេ។

១២- ខ្ញុំសូមអនុញ្ញាតចែករំលែកអនុសាសន៍មួយចំនួន តាមរយៈការសំយោគពីបទបង្ហាញ និងកិច្ចពិភាក្សាប្រកបដោយភាពរស់រវើកនៅមុននេះ សម្រាប់ជាការពិចារណា និងគិតគូរបន្ថែម។

- មួយ៖ ត្រូវពង្រីកការបញ្ជ្រាបការយល់ដឹងក្នុងចំណោមភាគីពាក់ព័ន្ធ។ នេះមិនត្រឹមតែជាការពិនិត្យលើសមិទ្ធផលនោះទេ តែត្រូវផ្តោតទៅលើការត្រៀមខ្លួន និងដាក់ផែនការសម្រាប់ការទទួលយក។
- ពីរ៖ កិច្ចសហការគ្នារវាងបណ្តាប្រទេសដែលបានចាកចេញពី LDC ដោយជោគជ័យ និងប្រទេសដែលកំពុងត្រៀមខ្លួន ដូចជាការចែករំលែកបទពិសោធន៍ ឧត្តមានុវត្តន៍ និងបញ្ហាប្រឈម ព័ត៌មាន និងជំនួយបច្ចេកទេសជាដើម។ ស្ថាប័នស្រាវជ្រាវដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលមួយនេះ។
- បី៖ ការចូលរួមពីដៃគូអភិវឌ្ឍន៍ តាមរយៈជំនួយហិរញ្ញប្បទាន និងបច្ចេកទេស ដើម្បីសម្រួលដល់ការត្រៀមខ្លួន និងសម្របខ្លួនក្រោយចាកចេញពីឋានៈ LDC។

១៣-សម្រាប់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា យើងក៏នឹងព្យាយាមជំរុញបន្ថែមទៅតាមលទ្ធភាពរបស់យើងក្នុងនាមជាស្ថាប័នស្រាវជ្រាវក្នុងប្រទេស ព្រមទាំងស្វាគមន៍នូវរាល់កិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីទាំងឡាយដែលផ្តល់ប្រយោជន៍ដល់សង្គមជាតិ។ យើងប្តេជ្ញា និងមានការរៀបចំការពិភាក្សា ការសិក្សា និងវាយតម្លៃអំពីប្រធានបទនេះ ឆ្ពោះទៅការសម្រេចបានចក្ខុវិស័យ២០៣០។

១៤- ជាកិច្ចបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀតចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី សិស្សនិស្សិត និងភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួមកិច្ចពិភាក្សាតុមូលនារសៀលនេះ ជាពិសេសវាគ្មិន និងអ្នកសម្របសម្រួលទាំងបួនរូប ដែលបានញ៉ាំងឱ្យកិច្ចពិភាក្សានេះ កាន់តែមានភាពរស់រវើក និងបានចូលរួមជាធាតុចូលដ៏មានអត្ថន័យលើប្រធានបទមួយនេះ។ ខ្ញុំទទួលស្គាល់ថារយៈពេល២ម៉ោងជាងនេះ មិនអាចឱ្យយើងមុជទៅជ្រៅនិងបានគ្រប់ជ្រុងជ្រោយទេ ប៉ុន្តែខ្ញុំក៏ជឿជាក់ថារយៈពេល២ម៉ោងជាងនេះ ជាពេលវេលាដែលអ្នកទាំងអស់គ្នាប្រើប្រាស់ដោយមានតម្លៃបំផុត ហើយមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា នឹងរៀបចំជាស៊េរីបន្តចំពោះប្រធានបទមួយនេះ។ ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សិស្សនិស្សិត និងភ្ញៀវកិត្តិយសទាំងអស់ ជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមជូនពរជ័យឆ្នាំថ្មីប្រពៃណីខ្មែរ ទាំងអស់គ្នា។

ខ្ញុំសូមប្រកាសបិទ កិច្ចពិភាក្សាតុមូល ស្តីពី «**ការវាយតម្លៃលើការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា**» នារសៀលនេះ។

**សូមគោរពអរគុណ!**

## IV. ឧបសម្ព័ន្ធទី១៖ របៀបវារៈនៃកម្មវិធីកិច្ចពិភាក្សាតុមូល

| ពេលវេលា | សកម្មភាព |
|---|---|
| ១៣:៣០ – ១៤:០០ | ការអញ្ជើញមកដល់នៃភ្ញៀវកិត្តិយស និងអ្នកចូលរួម |
| ១៤:០០ – ១៤:០៥ | គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា |
| ១៤:០៥ – ១៤:១៥ | សុន្ទរកថាបើកដោយ **ឯកឧត្តមបណ្ឌិត អ៊ុន យាង** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា |
| ១៤:១៥ – ១៦:១៥ | កិច្ចពិភាក្សាតុមូល៖ «**ការវាយតម្លៃការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា**»<br>- <u>វាគ្មិនពិភាក្សា</u>៖<br>១- **ឯកឧត្តមបណ្ឌិត គី សេរីវឌ្ឍន៍** ប្រធានវិទ្យាស្ថានសិក្សាចិន រាជបណ្ឌិត្យសភាកម្ពុជា<br>២- **បណ្ឌិត អ៊ុច ច័ន្ទតារ៉ានី** សេដ្ឋកិច្ចវិទូនៃការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា<br>- <u>អ្នកសម្របសម្រួល</u>៖ **លោកសាស្ត្រាចារ្យជំនួយ បណ្ឌិត យង់ គា** អនុប្រធានវិទ្យាស្ថានសិក្សាអន្តរជាតិ និងគោលនយោបាយសាធារណៈ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា |
| ១៦:១៥ – ១៦:២៥ | សុន្ទរកថាបិទដោយ **ឯកឧត្តម សុខន តារាពី** នាយករងមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា |
| ១៦:២៥ – ១៦:៣០ | ថតរូបអនុស្សាវរីយ៍ |